# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
លេខ ១៥៩/៩៩.សរណ

# ប្រធានតុលាការកំពូល

<u>ផ្ញើចប់</u>

# ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

<u>សូមជ្រាប។</u>

**<u>កម្មវត្ថុ:</u>** ការយឺតយ៉ាវក្នុងការចាត់ការរឿងព្រហ្មទណ្ឌដល់អង្គសេចក្តី នៅពេលមានការប្តឹងតវ៉ាអំពីដីកាឃុំខ្លួនជាបណ្តោះអាសន្ន ឬ ដីកាដោះលែងឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបអង្កេត ។

តុលាការកំពូល បានកត់សម្គាល់ឃើញថា នៅពេលមានការប្តឹងតវ៉ាអំពីដីកាឃុំខ្លួនជាបណ្តោះអាសន្ន ឬ អំពីដីកាឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុងៗតែងតែបញ្ជូនសំណុំរឿងដើមទាំងមូលមកសាលាឧទ្ធរណ៍ ហើយបន្តបញ្ជូនមកតុលាការកំពូលទៀត ដូច្នេះការស្រាវជ្រាវស៊ើបអង្កេត សម្រេចរឿងដល់អង្គសេចក្តីត្រូវផ្អាករង់ចាំសំណុំរឿងបញ្ជូនត្រឡប់ទៅវិញជាញឹកញយការឃុំខ្លួនបណ្តោះអាសន្នត្រូវហួសកំណត់ពេអនុញ្ញាត។ ការធ្វើដូច្នេះនាំឱ្យមានការយឺតយ៉ាវក្នុងការដោះស្រាយរឿងដល់អង្គសេចក្តី ។

តុលាការកំពូលយល់ឃើញថា តុលាការខេត្ត- ក្រុង គប្បីចាត់ការថតចម្លង ឯកសារដែលមានក្នុងសំណុំរឿងដើមហើយបញ្ជូនមកសាលាពុទ្ធរណ៍ តែសំណុំរឿងថតចម្លងបានហើយ ទន្ទឹមនេះក៏ត្រូវបន្តដោះស្រាយរឿងតាមកាលកំណត់ ។

សេចក្តីដូចបានជម្រាបជូននេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យ និងសម្រេចបើមិនយល់ទាស់ទេ សូមមេត្តាចាត់ការណែនាំទៅបណ្តុះតុលាការខេត្ត-ក្រុង ចំពោះសំណើនេះតាមការគួរ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

<u>ចម្លងជូន</u>
-តុលាការកំពូល និងមហាអយ្យការ
-សាលាឧទ្ធរណ៍ និងមហាអយ្យការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ដើម្បីជ្រាប